ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១២០/១០-ភីស៊ីស៊ីអេស**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៧នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ភីស៊ីស៊ីអេស ហ្គាមេន លីមីធីត**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៧៣ ៦១៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

១- លោក ឡុង ផល្លី ប្រធានធនធានមនុស្ស

២- លោក យូ ម៉េងទ្រី ប្រធានរដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ក/.ឈ្មោះ : **សហជីពសេរីកម្មករ នៃរោងចក្រ ភីស៊ីស៊ីអេស**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៤៦ ៤០៨ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

- លោកស្រី ពិន ពិសា អនុប្រធានសហជីព

ខ/.ឈ្មោះ : **សហជីពកម្មករភីស៊ីស៊ីអេស នៃរោងចក្រ ភីស៊ីស៊ីអេស**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែលសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៦៤៤ ៦៨១ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

១- លោក ឃិន វាសនា ប្រធានសហជីពកម្មករភីស៊ីស៊ីអេស

២- លោកស្រី សួន វិត អនុប្រធានសហជីព

គ/.ឈ្មោះ : **សហជីពខ្មែរ នៃរោងចក្រ ភីស៊ីស៊ីអេស**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែលសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៩២ ២២០ ៧៩១ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

១- លោកស្រី ឱម សំអុល ប្រធានសហជីពខ្មែរ នៃរោងចក្រ ភីស៊ីស៊ីអេស

២- លោកស្រី អៀប បុប្ផា អនុប្រធានសហជីព

៣- លោកស្រី មាជ សុផល លេខាធិការសហជីព

ឃ/.ឈ្មោះ : **សហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ នៃរោងចក្រ ភីស៊ីស៊ីអេស**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែលសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៩២ ៩៦៨ ៨៨១ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

- លោក ស៊ីន រតនៈ ប្រធានសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ

ង/.ឈ្មោះ : **សហជីពកម្មករកម្ពុជា នៃរោងចក្រ ភីស៊ីស៊ីអេស**

អាសយដ្ឋាន : ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែលសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៩៧ ៧៧៥ ១០៧២ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និងទី២:

១- លោកស្រី ពៅ ឡាប ប្រធានសហជីពកម្មករកម្ពុជា

២- លោកស្រី អ៊ុង សុវណ្ណី អនុប្រធានសហជីព

៣- លោកស្រី អ៊ុក ចន្ធី លេខាធិការសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនលើកផ្លាកសញ្ញាក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា មិនអាចកំណត់ថា លើកពេលណាទេ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១០១៥ កប/អក/វក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ : - លើកទី១ :** ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០ (វេលាម៉ោង ១៤ : ០០ នាទី រសៀល)

**- លើកទី២ :** ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១០ (វេលាម៉ោង ១៤ : ០០ នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ០៣ ចំណុចឱ្យកាន់តែប្រសើរឡើង ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញ ធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ដោយទទួលលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុចលើការទាមទារចំនួន ០៣ ចំណុច ។ ចំណុចមិនសះជាចំនួន ០១ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិត ស្នើសុំមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ពន្យាពេលសវនាការ គឺដើម្បីទុកពេលវេលាធ្វើការចរចារ សម្របសម្រួលជាមុនជាមួយនិយោជកសិន បើក្នុងករណីពុំទទួលបានសះជានឹងគ្នាទេ ទើបបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើចំណុចវិវាទនេះ។ ជាលទ្ធផល ភាគីកម្មករនិយោជិត និងនិយោជក ពុំមានឱកាសធ្វើការចរចានឹងគ្នាទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការអញ្ជើញភាគីទាំងពីរមកសវនាការជាលើកទី២ ដើម្បីស្វែងរកអង្គហេតុ និងព្យាយាមផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត នៅថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។ ប៉ុន្តែ ជាលទ្ធផល ពុំទទួលបានការសះជានឹងគ្នាទេ។ ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា ដោយផ្អែកលើភស្តុតាង និងហេតុផលដូចខាងក្រោមៈ

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកធនធានមនុស្ស និងរដ្ឋបាល នៃក្រុមហ៊ុន ភីស៊ីស៊ីអេស ជូនលោក ឡុង ផល្លី ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ។

២- លិខិតផ្ទេរសិទ្ធិរបស់នាយកធនធានមនុស្ស និងរដ្ឋបាល នៃក្រុមហ៊ុន ភីស៊ីស៊ីអេស ជូនលោក ឡុង ផល្លី ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ។

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ក្រុមហ៊ុន ភីស៊ីស៊ីអេស ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១០ ។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ភីស៊ីស៊ីអេស ។

៥- លក្ខន្តិកៈសហជីពក្រុមហ៊ុន ភិស៊ីស៊ីអេស ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១០ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

- បញ្ជីរាយនាមឈ្មោះសហជីពដែលចូលរួមសវនាការនៅលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភីស៊ីស៊ីអេស លេខ ១០១៥ កប/អក/វក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ភីស៊ីស៊ីអេស ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៦៣៤ កប/អក/វក/លកអ. ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៦៣៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៦៨៥ កប/អក/វក/លកអ. ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៦៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ភីស៊ីស៊ីអេស បង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ ហើយក្រុមហ៊ុននេះមានជួលកម្មករនិយោជិត ចំនួនប្រហែល ៣៣៣៤ នាក់។
- សហជីពកម្មករកម្ពុជា សហជីពកម្មករ សហជីពសេរីកម្មករ សហជីពខ្មែរ និងសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ និងតំណាងឱ្យកម្មករនិយោជិត ចំនួន ៩៥៦ នាក់។

**ចំណុចវិវាទ: កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនលើកផ្លាកសញ្ញាក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ**

- ភាគីកម្មករនិយោជិតបានលើកឡើងថា មូលហេតុដែលពួកគាត់ទាមទារនេះ គឺចង់ឱ្យក្រុមហ៊ុនមាន ដាក់ផ្លាកសញ្ញា ភីស៊ីស៊ីអេស ដូចពេលមុន ពោលចង់ឱ្យមនុស្សទូទៅដឹងថា នេះគឺជាក្រុមហ៊ុន ភីស៊ីស៊ីអេស។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កន្លងមកក្រុមហ៊ុនមានដាក់ផ្លាកត្រឹមត្រូវ ប៉ុន្តែ ឥឡូវ ក្រុមហ៊ុនអត់មានផ្លាក ធ្វើឱ្យកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុនពុំមានទំនុកចិត្តទេ ពួកគាត់មានការបារម្ភ និងភ័យខ្លាចថា ក្រុមហ៊ុនឈប់ដំណើរការ ហើយរត់ចោលពួកគាត់ ដោយពុំ បានជូនដំណឹងជាមុន។
- ភាគីនិយោជកបានលើកឡើងថា កន្លងមកមានផ្លាកសញ្ញាក្រុមហ៊ុនមួយដែលដាក់តាំងនៅពីលើអាគារ ក្រុមហ៊ុន។ ផ្លាកសញ្ញានេះមានទទឹងប្រវែង ១.៥ ម៉ែត្រ និងបណ្តោយ ៤០ ម៉ែត្រ។ ប៉ុន្តែ ដោយសារ ថៃដន្យមានរន្ទះមួយបានបាញ់ត្រូវជើងផ្លាក និយោជក ក៏ទំលាក់ផ្លាកនោះចេញ បន្ទាប់មកនិយោជក ក៏បានប្តូរដាក់ផ្លាកយីហោក្រុមហ៊ុន ភីស៊ីស៊ីអេស ថ្មី ដែលមានទំហំតូចជាងមុន គឺទទឹងមានប្រវែង ១ ម៉ែត្រ និងបណ្តោយមានប្រវែង ១ ម៉ែត្រ ប៉ុណ្ណោះ។ ចៃដន្យនៅពេលនោះមាន កូដកម្មមួយបាន កើត ឡើង ដែលធ្វើឱ្យក្រុមហ៊ុនសម្រេចដកយកផ្លាកសញ្ញាដែលទើបនឹងប្តូរនោះចេញវិញ។ ភាគីនិយោជក បានបញ្ជាក់ថា និយោជកនឹងមានគំរោងលើកផ្លាកសញ្ញា ភីស៊ីស៊ីអេស នេះឡើងវិញ ប៉ុន្តែពុំទាន់ សន្យាថា នៅពេលណាទេ ព្រោះត្រូវរង់ចាំគិតរកពេលវេលា និងទីតាំងល្អ។ ចំពោះបញ្ហានេះ និយោជកមានគំរោងនឹងអាចរៀបចំនៅក្នុងឆ្នាំថ្មីខាងមុខនេះ ព្រោះនេះ គឺជាជំនឿដែលនិយោជក ត្រូវការគិតពិចារណា នឹងរកពេលវេលាល្អ មុននឹងសម្រេចលើកផ្លាកនេះឡើងវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ការពុំបានដាក់ផ្លាកសញ្ញាសំគាល់របស់ក្រុមហ៊ុន គឺពុំបានប៉ះពាល់ ទៅនឹងប្រាក់ឈ្នួល ឬលក្ខខណ្ឌការងារទូទៅនោះទេ គឺវានៅរក្សាដដែល។
- នៅក្នុង សវនាការភាគីកម្មករនិយោជិតបានអះអាងទៀតថា កម្មករនិយោជិតចង់ធ្វើកូដកម្មឱ្យ ក្រុមហ៊ុនលើកផ្លាកយីហោក្រុមហ៊ុន ប៉ុន្តែ សហជីពបានណែនាំកម្មករនិយោជិតឱ្យរង់ចាំការចរចា និងដោះស្រាយ តាមនីតិវិធី សិន។

**ហេតុផលនៃសេចក្តីសម្រេច:**

**ចំណុចវិវាទ: កម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនលើកផ្លាកសញ្ញាក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើវិវាទដែលកម្មករនិយោជិតនាំមក ជាវិវាទការងាររួមដែល ស្ថិតនៅក្រោមយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែរឬទេ?

មាត្រា ៣០២ នៃច្បាប់ស្តីពីការងារ បានចែងថា "*វិវាទការងាររួម គឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ និងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និងកម្មករនិយោជិត ហើយការវិវាទនេះអាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើខូច សន្តិភាពសង្គម* ។

ផ្អែកលើមាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ដើម្បីអាចនិយាយបានថា វិវាទមួយជាវិវាទរួម ត្រូវបំពេញជាចាំបាច់តាមលក្ខខណ្ឌបីយ៉ាងនៃវិវាទការងាររួម ដូចមានចែងក្នុងច្បាប់ការងារមាត្រា ៣០២។ លក្ខខណ្ឌបីយ៉ាងនោះ គឺ *ក- ជាវិវាទរវាងកម្មករមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់, ខ- បញ្ហានៃវិវាទទាក់ទង នឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬបញ្ហានៃទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត និង គ- វិវាទនេះអាចបណ្តាលអាចឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម*។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦១/១០-ស៊ីនទ្រី) ។

យោងទៅតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាដូចខាងក្រោម:

**ក- វិវាទរវាងកម្មករមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់ :** នៅក្នុងសំណុំរឿងនេះ វិវាទបានកើតឡើងរវាងសហជីពចំនួន ៥ ដែលតំណាងឱ្យកម្មករនិយោជិតនៅក្នុងរោងចក្រ និងនិយោជកនៃក្រុមហ៊ុន ភីស៊ីស៊ីអេស ដូច្នេះលក្ខខណ្ឌ **ក** ត្រូវបានបំពេញ។

**ខ- បញ្ហាទាក់ទងនឹងលក្ខខណ្ឌការងារ :** វិវាទបានកើតឡើងទាក់ទងទៅនឹងការទាមទារការលើកផ្លាកសញ្ញាយីហោក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ ដោយហេតុថា កម្មករនិយោជិតមានការបារម្ភខ្លាច ក្រុមហ៊ុនឈប់ដំណើរការដោយមិនមានការជូនដំណឹងជាមុន។ ទាក់ទងទៅនឹងការដែលនិយោជក ពុំបានលើកផ្លាកសញ្ញាបញ្ជាក់ថា ជាក្រុមហ៊ុន ភីស៊ីស៊ីអេស នេះ កម្មករនិយោជិតពុំទទួលរងនូវការខូចខាត និងទទួលការប៉ះពាល់ទៅនឹងលក្ខខណ្ឌការងារទូទៅ និងអត្ថប្រយោជន៍ផ្សេងៗ ដូចជា ម៉ោងធ្វើការ ឬប្រាក់ឈ្នួល ឬសិទ្ធិដែលពួកគាត់ធ្លាប់ទទួលបានកន្លងមកនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចបញ្ហាវិវាទនេះ មិនទាក់ទងទៅនឹងលក្ខខណ្ឌការងារ សិទ្ធិ និងកាតព្វកិច្ចនៅក្នុងកិច្ចសន្យាការងារ ដែលនិយោជកត្រូវអនុវត្តចំពោះកម្មករនិយោជិតនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌ **ខ** មិនត្រូវបានបំពេញនោះឡើយ ។

**គ- បណ្តាលឱ្យមានការរាំងស្ទះដំណើរការសហគ្រាស :** ទន្ទឹមនឹងនេះដែរ យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតមានបំណងនឹងធ្វើកូដកម្មដើម្បីទាមទារឱ្យក្រុមហ៊ុនលើកផ្លាកសញ្ញា ភីស៊ីស៊ីអេស ឡើងវិញ។ ទង្វើនេះនឹងអាចធ្វើឱ្យមានការរាំងស្ទះដំណើរការរបស់ក្រុមហ៊ុន ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ ថា លក្ខខណ្ឌ **គ** ត្រូវបានបំពេញ ។

តាមការបកស្រាយខាងលើ ការទាមទាររបស់កម្មករនិយោជិតមិនបានបំពេញនូវលក្ខខណ្ឌ ១ ក្នុងចំណោមលក្ខខណ្ឌទាំងបីនោះទេ។ ដូច្នេះ វិវាទនេះមិនមែនជាវិវាទការងាររួមតាមច្បាប់ស្តីពីការងារ ដូចនេះ ក្រុមប្រឹក្សា

អាជ្ញាកណ្តាល ពុំមានយុត្តាធិការក្នុងការពិចារណា និងសម្រេចលើចំណុចវិវាទនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតដែលឱ្យនិយោជកលើកផ្លាកសញ្ញាក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ ។

## សម្រេច និង បង្គាប់

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកលើកផ្លាកសញ្ញាក្រុមហ៊ុន ភីស៊ីស៊ីអេស ឡើងវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :
ឈ្មោះ : **អ៊ុំ សុន្ធី**
ហត្ថលេខា: ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :
ឈ្មោះ : **អាន វីរៈ**
ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :
ឈ្មោះ : **អាំង អេងថុង**
ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL